FARMER NOTES
ព្រឹត្តិប័ត្រព័ត៌មានកសិករ
ឆ្នាំទី ៦ លេខ ៥៧ ខែកុម្ភៈ ឆ្នាំ ២០០៧
ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute



# អំបូរកណ្តុរដែលបំផ្លាញដំណាំស្រូវនៅប្រទេសកម្ពុជា

## ១- កម្រិតនៃការបំផ្លាញរបស់សត្វកណ្តុរស្រែ

កណ្តុរគឺជាសត្វចង្រៃដ៏ចម្បងបំផុតលើដំណាំកសិកម្មក្នុងតំបន់មួយចំនួននៃប្រទេសកម្ពុជាយើង។ ការបំផ្លាញរបស់វាធ្វើឲ្យមានការបាត់បង់ទិន្នផលគួរឲ្យកត់សម្គាល់នៅមុនពេលប្រមូលផលស្រូវ។ តាមការពិសោធន៍ស្រាវជ្រាវ បានបង្ហាញឲ្យឃើញថា ការបាត់បង់ទិន្នផលស្រូវ ទាំងមុនពេលប្រមូលផល និងក្រោយពេលប្រមូលផលដោយសារសត្វកណ្តុរ មានជាមធ្យមពី ៥ - ១៥ ភាគរយ និងស្ទើរទាំងស្រុងនៅឆ្នាំខ្លះ (ឆ្នាំកើតមានកណ្តុរច្រើន)។ កម្រិតនៃការបំផ្លាញរបស់កណ្តុរអាស្រ័យទៅលើបរិមាណនៃជម្រកសមស្របរបស់ពួកវាដែលស្ថិតនៅជុំវិញស្រែ។ ដោយហេតុនេះហើយ កម្រិតនៃការបំផ្លាញពីតំបន់មួយទៅតំបន់មួយទៀតនៅតាមភូមិ មិនមានលក្ខណៈដូចគ្នាឡើយ ហើយការបំផ្លាញនេះ ច្រើនប្រមូលផ្តុំនៅតាមព្រៃភូមិដែលមានប្រឡាយដុះដោយស្មៅ ស្រះធំៗ និងបឹង។

## ២- លទ្ធភាពបន្តពូជ

សត្វកណ្តុរអាចបន្តពូជយ៉ាងលឿននៅពេលមានលក្ខខណ្ឌសមប្រកប។ ដោយផ្អែកទៅតាមលក្ខខណ្ឌចំណីអាហារគ្រប់គ្រាន់ កណ្តុរញីមួយក្បាលអាចមានកូនបីដងក្នុងមួយរដូវ ហើយដែលចំនួនកូនក្នុងមួយដងគឺពី ៦ ទៅ ៨ ក្បាល ដូចនេះកណ្តុរមេបាមួយគូអាចបង្កើតកូនចៅបានរហូតដល់ជាង ៥០០ ក្បាល ក្នុងមួយឆ្នាំ។

## ៣- អំបូរកណ្តុរស្រែ

ឆ្លងតាមទិន្នន័យនៃការពិសោធន៍ស្រាវជ្រាវចំនួនប្រាំពីររាជធានី ខេត្ត ក្រុង ដែលរួមមានរាជធានីភ្នំពេញ កំពង់ចាម កំពង់ឆ្នាំង បាត់ដំបង តាកែវ សៀមរាប និងបន្ទាយមានជ័យ បានរកឃើញអំបូរកណ្តុរចម្បងៗដែលបំផ្លាញស្រូវក្នុងប្រទេសកម្ពុជា មាន ៩ អំបូរគឺ៖



១- អំបូរកណ្តុរប្បាយ ឬកណ្តុរប្រផេះ *(Rattus argentiventer)* ៖ មានប្រវែងក្បាល និងដងខ្លួនប្រមាណ ២០៤ មីល្លីម៉ែត្រ ដោយមានរោមក្រហមត្នោត។ រោមពោះពណ៌ទឹកប្រាក់ និងមានឆ្នូតខ្មៅនៅលើជើងក្រោយ។ ពួកវាត្រូវបានគេប្រទះឃើញនៅតំបន់ដាំដុះស្រូវទំនាបក្នុងភាគខាងលិច និងខាងត្បូងនៃប្រទេសកម្ពុជា។ កណ្តុរអំបូរនេះ រស់នៅដោយស៊ីស្រូវ ជាពិសេសពេលស្រូវនៅដំណាក់កាលផើមដល់ដំណាក់កាលស្រូវទុំ។ វាគឺជាប្រភេទសត្វចង្រៃមួយក្នុងចំណោមសត្វចង្រៃផ្សេងៗក្នុងតំបន់ជាច្រើននៃប្រទេសកម្ពុជា។



២- អំបូរកណ្តុរប្បាយតូច *(Rattus losea)* ៖ មានប្រវែងក្បាល និងដងខ្លួនដូចគ្នាទៅនឹងអំបូរកណ្តុរបាយដែរ និងមានរោមពណ៌ក្រហម រោមពោះពណ៌ប្រផេះ និងកន្ទុយពណ៌ខ្មៅ។ ពួកវាត្រូវបានគេប្រទះឃើញមាននៅតំបន់ដាំដុះស្រូវទំនាបក្នុងប្រទេសកម្ពុជា ប៉ុន្តែគេប្រទះឃើញនៅកន្លែងដែលមិនមែនមានស្រូវតែមួយមុខនោះទេ ឧទាហរណ៏ដូចជាកន្លែងតំបន់ដីខ្ពស់គម្ពោតព្រៃ ឬកន្លែងដែលមានដើមឈើជុំវិញភូមិ។ សត្វកណ្តុរអំបូរនេះមានឃើញនៅតំបន់ដីសណ្តរនៅខេត្តតាកែវ ដែលមានតែស្រូវ។ ពួកវារស់នៅភាគច្រើននៅក្នុងរូងដី។ សត្វកណ្តុរទាំងនេះរស់នៅដោយស៊ីស្រូវ និងគ្រាប់ពូជផ្សេងទៀត ហើយក៏អាចស៊ីសត្វល្អិតផងដែរ។



៣- អំបូរកណ្តុរត្នោត *(Rattus rattus)* ៖ ជាសត្វកណ្តុរដែលមានប្រវែងក្បាល និងដងខ្លួនដូចគ្នាទៅនឹងអំបូរកណ្តុរបាយតូច និងមានពណ៌ត្នោតទៅក្រហមត្នោត ប៉ុន្តែពណ៌របស់ពួកវាអាចខុសគ្នា។ សត្វកណ្តុរខ្លះមានពណ៌ស និងខ្លះទៀតមានពណ៌ប្រផេះ កណ្តុរត្នោតអំបូរនេះត្រូវ

បានគេប្រទះឃើញនៅក្នុងជម្រកជាច្រើនក្នុងប្រទេសកម្ពុជា ដូចជានៅតាមវាលស្រែ ដំណាំតាមភូមិ ផ្ទះ និងតាមព្រៃ។ វាអាចចល័តបានទៅគ្រប់ទីកន្លែង ព្រោះវាអាចឡើងចុះ ទៅមកបានល្អ និងអាចរស់នៅតាមដំបូលផ្ទះ ឬក៏ដើមឈើ ហើយអាចរស់នៅក្នុងរូងដីបានដែរ។ ពួកវារស់នៅដោយស៊ីស្រូវ (រួមទាំងសំណាប) ដំណាំដំទៃទៀត គ្រាប់ធញ្ញជាតិដែលគេស្តុកទុក សត្វល្អិត និងពងសត្វ។ល។



៤- អំបូរកណ្តុរអង្គាមផ្ទះ *(Rattus exulans)* ៖ វាមានក្បាល និងដងខ្លួនប្រវែងខ្លីជាង ១២០ មីល្លីម៉ែត្រ ហើយមានរោមពណ៌ត្នោតលាត ដោយមានកន្ទុយវែង និងជើងតូច។ គេឃើញមាននៅតែតាមទីក្រុង និងនៅតាមភូមិក្នុងតំបន់មួយចំនួនតែប៉ុណ្ណោះ។ ពេលខ្លះវាក៏ត្រូវបានគេប្រទះឃើញនៅក្នុងស្រែផងដែរ។ ពួកវារស់នៅក្នុងផ្ទះ និងដំបូលផ្ទះដែលជាកន្លែងអាចធ្វើសម្បុកតូចៗបានដោយមិនបាច់មានចំបើង និងកម្ទេចកំទីដំទៃទៀតឡើយ ហើយស៊ីស្រូវក្នុងជង្រុក និងកាកសំណល់ចំណីអាហារតាមផ្ទះ។



៥- អំបូរកណ្តុរប្រែងប្រផេះ *(Rattus novergicus)* ៖ ជាអំបូរកណ្តុរធំ មានប្រវែងក្បាល និងដងខ្លួនប្រហែល ២៥០ មីល្លីម៉ែត្រ មានពណ៌ប្រផេះ និងជើងពណ៌សធំ។ កណ្តុរអំបូរនេះ ជាទូទៅគេច្រើនសង្កេតឃើញមានស្នាមនៅលើខ្លួនវា ឬដាច់រលាត់រេចរោមដោយសារពេលរស់នៅជាមួយគ្នា ពួកវាតែងខាំគ្នាជាញឹកញាប់។ នៅក្នុងប្រទេសកម្ពុជា គេសង្កេតឃើញនៅតាមទីក្រុងធំៗ។ ពួកវាបង្កបញ្ហាខ្លាំងក្លាជាងគេនៅតាមភោជនីយដ្ឋាននៅក្រុងភ្នំពេញ។ ពួកវាក៏ប្រទះឃើញផងដែរនៅតាមឃ្លាំងធំៗ។ ជួនកាលគេប្រទះឃើញនៅតាមវាលស្រែ ជាកន្លែងដែលរស់នៅជាក្រុមធំៗនៅជុំវិញអណ្តូង ឬភ្លឺស្រែធំៗ ក្នុងរូងធំជាមួយសត្វកណ្តុរផ្សេងៗទៀត។ សត្វកណ្តុរអំបូរនេះស៊ីចំណីស្ទើរគ្រប់ប្រភេទដែលវាប្រទះឃើញ។



៦- អំបូរកណ្តុរប្រែងធំ *(Bandicota indica)* ៖ ជាអំបូរសត្វកណ្តុរដែលធំជាងគេ ប្រវែងក្បាល និងដងខ្លួនអាចមានប្រវែងប្រមាណ ២៩០ មីល្លីម៉ែត្រ រោមមានពណ៌ប្រផេះទៅពណ៌ខ្មៅ រោមជើងធំៗ និងមានរោមវែងៗពណ៌ខ្មៅនៅលើខ្នង។ អំបូរកណ្តុរប្រែងធំ ត្រូវបានគេប្រទះឃើញនៅគ្រប់ប្រព័ន្ធក្រេត្យបរិស្ថានដាំដុះដំណាំស្រូវក្នុងប្រទេសកម្ពុជា។ ពួកវារស់នៅក្នុងរូងធំៗក្រោមដី និងស៊ីស្រូវគ្រប់ដំណាក់កាលទាំងអស់។ ពួកវាបន្សល់ទុកនូវសញ្ញាឲ្យឃើញនៅក្នុងវាលស្រែដែលពួកវាស៊ីបំផ្លាញ។ ចំណីរបស់វាមានដូចជាក្តាម ខ្យង និងគ្រាប់ធញ្ញជាតិដំទៃទៀតដែលគេប្រទះឃើញនៅក្នុងវាលស្រែ។

៧- អំបូរកណ្តុរប្រែងខ្មៅ *(Bandicota savilei)* ៖ មានលក្ខណៈស្រដៀងគ្នាទៅនឹងអំបូរកណ្តុរប្រែងធំ តែខុសគ្នាត្រង់មានទំហំតូចជាង



មានរោមប្រផេះជាងបន្តិច មានជើងតូចជាង និងគ្មានរោមពណ៌ខ្មៅនៅលើខ្នងទេ។ ពួកវាមានរាយប៉ាយក្នុងប្រទេសកម្ពុជា និងស៊ីចំណីដូចកណ្តុរប្រែងធំដែរ។



៨- អំបូរកណ្តុរស្រែអង្គាម *(Mus caroli)* ៖ មានប្រវែងក្បាល និងដងខ្លួនប្រមាណ ៧៨ មីល្លី-ម៉ែត្រ រោមពណ៌ប្រផេះច្បាស់ និងមានជើងតូចៗ។ គេប្រទះឃើញសត្វកណ្តុរអំបូរនេះនៅតែក្នុងស្រែប៉ុណ្ណោះ។ ពួកវារស់នៅក្នុងរូងតូចៗ ឬនៅក្នុងរូងសត្វកណ្តុរផ្សេងៗទៀត ឬកាច់សម្បុកក្នុងគំនរចំបើងដែលគេបានបន្សល់ទុកក្នុងស្រែ។ វាឡើងដើមស្រូវ កាត់កួរស្រូវស៊ីបំផ្លាញពេលស្រូវទុំ និងកួរស្រូវដែលនៅសល់ក្នុងស្រែ។



៩- អំបូរកណ្តុរស្រែអង្គាមតូច *(Mus cervicolor)* ៖ វាបំផ្លាញដំណាំស្រូវមានលក្ខណៈដូចអំបូរកណ្តុរស្រែអង្គាមដែរ ប៉ុន្តែទំហំរបស់វាតូចជាងបន្តិច និងមានកន្ទុយខ្លីជាងប្រវែងក្បាល និងដងខ្លួន។

សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យការពារដំណាំ មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យដៃគូការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ ភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ គេហទំព័រ: www.cardi.org.kh
ទូរអក្សរ: plap@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh